**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣៥៧
ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩
**សាលដីកា**
លេខៈ២៤៦
ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រមរបាយការណ៍
៣-លោក ............. ជាចៅក្រម
៤-លោក .............. ជាចៅក្រម
៥-លោក ............... ជាចៅក្រម
៦-លោក ............... ជាចៅក្រម
៧-លោក ............... ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ................

**តំណាងមហាអយ្យការ**

-ឯកឧត្តម ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ពីសាលដីការដ្ឋប្បវេណីលេខ៤១៧ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥៤ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍រវាង ដើមចោទឈ្មោះលយន (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរមុខរបរ គ្រូបង្រៀន ទីលំនៅសព្វថ្ងៃភូមិព្រែកសំពោង ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល។ឪពុកឈ្មោះហៀក លី(ស) ម្តាយឈ្មោះទី ហ៊ាង (រ) ប្រពន្ធឈ្មោះហ៊ត មួយ ។

ចុងចម្លើយឈ្មោះសគ (ជំម្ទាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរមុខរបរធ្វើចំការ ទីលំនៅសព្វថ្ងៃភូមិព្រែកសំពោង ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល ។ឪពុកឈ្មោះសំ (ស) ម្តាយឈ្មោះដឹង ង៉ោ (ស) ប្រពន្ធឈ្មោះឃុយ ហ៊ាង ។

**<u>កម្មវត្ថុបណ្តឹង</u>**: ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ៣៣៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩របស់ឈ្មោះសគ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤១៧ ចុះថ្ងៃទី០៨ ខែកក្កដាឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៥៧ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១០-០២-៩៦ ដើមចោទឈ្មោះលយន បានប្តឹងសុំទាមទារសិទ្ធិកាន់កាប់ និងទាមទារឱ្យឈ្មោះសគ លុះរើរបងចេញពីដីរបស់ខ្លួន ដោយហេតុថា ដីនេះខ្លួនបាន កាន់កាប់តាំងពីឆ្នាំ១៩៧៩ ហើយបានបេះផ្លែល្មុតរហូតដល់បច្ចុប្បន្ន ។ លុះដល់ឆ្នាំ១៩៨៣ ឈ្មោះសគ បានធ្វើសិប្បកម្មផ្គាំនៅជិតដីរបស់ខ្លួន ហើយយកម្លប់ចំការល្មុតរបស់ខ្លួនជាកន្លែងរៀបសន្លឹកថ្នាំ ប៉ុន្តែក្នុងនោះផលល្មុតខ្លួននៅតែបេះដោយគ្មានទំនាស់អ្វីឡើយរហូតដល់ឆ្នាំ១៩៩២-៩៣ សំគង់ ឈប់ធ្វើឡផ្ទាំស្រាប់តែឈ្មោះនេះបានធ្វើរបងព័ទ្ធដីចំការល្មុតមិនឱ្យខ្លួនបេះល្មុត ជាហេតុនាំឱ្យមាន ទំនាស់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣០(គ) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកណ្តាលដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១០-០២-៩៦ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះសគ ប្រគល់សិទ្ធិកាន់កាប់ដីទំហំ១៥ម៉ែត្រ បណ្តោយ១០៦ម៉ែត្រ ដែលមានព្រំប្រទល់ខាងជើងទល់ដីឈ្មោះស៊ាប ប៉ាវស្រី ខាងត្បូងទល់ដីឈ្មោះឡេង ផាន ខាងកើតទល់ទន្លេបាសាក់ និងខាងលិចទល់ដីឈ្មោះលយន ស្ថិតនៅក្នុងភូមិព្រែកសំរោង ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល ។ ឱ្យទៅឈ្មោះលយន គ្រប់គ្រងប្រើប្រាស់ជាកម្មសិទ្ធិតទៅ ។

៣-បង្គាប់ឱ្យឈ្មោះសគ គាស់ដំណាំ និងរុះរើរបងចេញពីដីកម្មសិទ្ធិរបស់ឈ្មោះលយន ចាប់តាំងពីសាលក្រមចូលជាស្ថាពរ ។

៤-បង្គាប់ឱ្យឈ្មោះសគ បង់ប្រាក់ប្រដាប់ក្តីសរុប៧.០០០៛ ក្នុងនោះពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តីចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ និងពន្ធលើការស៊ើបអង្កេត៥.០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ តែឱ្យចុងចម្លើយសងទៅដើមចោទវិញ និងបង្គាប់ឱ្យឈ្មោះសគ បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃសរុប១.០០០.០០០៛ (មួយលានរៀល) ស្មើទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤៨(បេ) ចុះថ្ងៃទី១៦-០២-៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៧៤ ចុះថ្ងៃទី២៣-០៣-៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០៛ ដែលលោកលយន បានបង់រួចហើយគឺ

- ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយ តម្រូវឱ្យលោកសគសងប្រាក់ចំនួន១៩.០០០៛ នេះ ទៅលោកលី យ៉ាវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤១៧ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសារឡើងវិញនូវរឿងក្ដីនេះតាមអំណាចសាលដីការបស់តុលាការកំពូលលេខ១៨២ ចុះថ្ងៃទី២៥-០៨-៩៨ ។

២-តម្កល់សាលក្រមលេខ៣០(ក) ចុះថ្ងៃទី២៧-០៩-៩៦ របស់តុលាការខេត្តកណ្ដាល ទុកជាបានការពេញទាំងមូលដដែល ។

៣-សាលដីកាលើកទី២នេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដីបើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ៣៣៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះសគប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤១៧ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការបស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ។

បានស្ដាប់ចម្លើយរបស់ឈ្មោះលយន នាពេលសវនាការថា ដីនេះខ្លួនបានកាន់កាប់រហូតមក ហើយបច្ចុប្បន្នចុងចម្លើយ បានឈប់នៅទីនោះហើយ ។

នឹង១០.០០០៛ ក្នុងនោះរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស $\frac{\text{១០០០០x២០}}{\text{១០០}}$ =២.០០០រៀល ។ និងបង់ចូលថវិការដ្ឋ$\frac{\text{១០០០០x៨០}}{\text{១០០}}$=៨.០០០រៀល ។

៥-សាលក្រមនេះជំនុំជំរះ ជាសាធារណៈចំពោះមុខដើមចោទ បើកផ្លូវឧទ្ធរណ៍រយៈពេល២ខែ និងកំបាំងមុខចុងចម្លើយ ទុកសិទ្ធិឱ្យប្ដឹងទាស់រយៈពេល១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹង និងប្ដឹងឧទ្ធរណ៍រយៈពេលពីរខែ ក្រោយពីផុតកំណត់ប្ដឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៣៥ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់ឈ្មោះសគ ប្តឹងមិនសុខចិត្តនឹងសាលក្រមទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៨(បេ) ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១-១១-៩៦ របស់ឈ្មោះសគ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៣០(គ) ៣១(គ) និង៣២(គ) ចុះថ្ងៃទី២៧-០៩-៩៦ របស់តុលាការខេត្តកណ្តាល ចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ ស្ថិតនៅភូមិព្រែកសំរោង ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល រវាងឈ្មោះលយន ស៊ាប ប៉ាវស្រ៊ ឡេង ឈូ និងឈ្មោះសគ ទៅឱ្យឈ្មោះសំគង់ គ្រប់គ្រងនិងកាន់កាប់ជាកម្មសិទ្ធិតាមច្បាប់តទៅ ។ មាត្រា៦២,៧២ និង៧៤ នៃច្បាប់ភូមិបាល។

៤-សម្រេចកាត់យកប្រាក់ប្រដាប់ក្តីចំនួន១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួចហើយ និងបង្គាប់ឱ្យចុងបណ្តឹងឧទ្ធរណ៍សងប្រាក់ចំនួន១៣.០០០៛ នេះទៅដើមបណ្តឹងឧទ្ធរណ៍វិញ ។ ប្រាក់នេះចំណាយលើពន្ធចុះបញ្ជីក្តី និងពន្ធហ្វីង២៥៥០៛ រង្វាន់ក្រឡាបញ្ជីសរុប១៣.០០០៛ ។ កាលបើហួសបណ្តឹងសាទុក្ខ បង្គាប់ឱ្យចុងបណ្តឹងឧទ្ធរណ៍ បង់ពន្ធសមាមាត្រ មួយភាគរយលើតម្លៃដីទំនាស់ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ឈ្មោះលយន ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៨២ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ដែលមានអ្វីមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី១៦-១២-៩៨ របស់លោកលីយ៉ានី

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាបហើយ .

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៣៣៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោកសគ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងតាមមាត្រា២២៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ពុំមានភស្ដុតាងណាបញ្ជាក់ថា ដីទំនាស់នេះ រដ្ឋអំណាចបានប្រគល់ឱ្យលោកសគទេ ដីដែលរដ្ឋអំណាចប្រគល់ឱ្យលោកសគ ធ្វើឡថ្នាំ គឺនៅចម្ងាយ៥ម ពីដីចំការល្ហុតដែលជាដីទំនាស់ ។

- យល់ឃើញថា ដីទំនាស់នេះ ដើមចោទបានកាន់កាប់ និងអាស្រ័យផលតាំងពីឆ្នាំ១៩៧៩ ជាប់ជាអចិន្ត្រៃហូតដល់បច្ចុប្បន្ន ដោយមានការទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋានត្រឹមត្រូវ ដូច្នេះដើមចោទមានសិទ្ធិលើដីទំនាស់នេះតាមមាត្រា៦២ និង៧៤ នៃច្បាប់ភូមិបាលចាស់ហើយ ។

- យល់ឃើញថា ដីទំនាស់នេះ តាំងពីមុនពេលទំនាស់រហូតដល់បច្ចុប្បន្នស្ថិតនៅក្រោម ការកាន់កាប់របស់ដើមចោទទៅហើយ ដូច្នេះពុំគប្បីសម្រេចអំពីពន្ធសមាមាត្រទេ ។

- យល់ឃើញថាលោកសគ បានទទួលលិខិតបង្គាប់ឱ្យធ្វើសារណាហើយ ប៉ុន្តែលោកពុំបានធ្វើសារណាជូនមកតុលាការកំពូលទេ តុលាការក៏បានកោះហៅលោកសំគង់ មកចូលរួមនាសវនាការដែរហើយ ប៉ុន្តែការកោះហៅលើកទី១ និងលើកទី២ នេះ រដ្ឋអំណាចឃុំកោះធំ (ខ) បានបញ្ជាក់ថាឈ្មោះសគ មិនដឹងនៅទីណាទេ រកមិនឃើញ ដូច្នេះដើម្បីកុំឱ្យអូសបន្លាយពេលវេលាតទៅទៀត តុលាការកំពូលសម្រេចជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤១៧ ចុះថ្ងៃទី០៨-០៧-១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្ដីចំពោះចម្លូងដើមចោទ កំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ៣៣៣៨ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោកសគ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស និងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៤១៧ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែប្រាក់ពន្ធសមាមត្រដែលត្រូវទុកជាមោឃៈ ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីដែលចុងចម្លើយបានបង់នៅតុលាការកំពូលចំនួន១៩០០០៛ គឺៈ

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤ ។